ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

# ដំណាំក្រូចពោធិសាត៏



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយៈ

ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៦




**អាសយដ្ឋាន** : អគារលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : (០២៣) ២១៥ ៨១៩/០១២ ៨៣ ៧៩ ៤៥

**ទូរសារលេខ** : (៨៥៥)២៣ ២១០ ៩៤៨

**Facebook** : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម - **Department of Agricultural Extension**

**គេហទំព័រ** : **http://www.maff.gov.kh**

# សៀវភៅ

# ស្តីពី

# ដំណាំក្រូចពោធិសាត់

## រៀបចំដោយ


## នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម



បោះពុម្ពលើកទី១ ចំនួន ២០០០ច្បាប់

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



រក្សាសិទ្ធិដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្តីពីដំណាំក្រូចពោធិសាត់

## I. ទីប្រឹក្សាផ្តល់យោបល់:

១. បណ្ឌិត **ម៉ាក់ សឿន** អគ្គនាយកដ្ឋានកសិកម្ម

២. បណ្ឌិត **ម៉ៅ មីនា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **ប៉ែន ឧុទ្ធី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **គឹម ដារ៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

## II. អ្នករៀបរៀង:

១. លោក **ផាន ទូច** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

## III. ក្រុមការងារស្រាវជ្រាវ:

១. លោក **នូ ប្រណិត** មន្ទីរកសិកម្មខេត្តបាត់ដំបង

២. កញ្ញា **ឌិម ណារី** មន្ទីរកសិកម្មខេត្តបាត់ដំបង

## IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

១. លោក **ពេជ សុខន្ថារ៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

២. លោក **ហុខ ទ្រី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោកស្រី **ចាន់ សុធី** នាយកដ្ឋានសាវប្បកម្ម និងដំណាំរួមផ្សំ

៤. លោក **កេត សំអាត** នាយកដ្ឋានសាវប្បកម្ម និងដំណាំរួមផ្សំ

## មាតិកា

ទំព័រ


I. សារៈប្រយោជន៍........................................០១

II. តំបន់ដាំដុះ...............................................០៣

III. បច្ចេកទេសដាំដុះ និងការថែទាំ.....................០៤

១. បច្ចេកទេសជ្រើសរើសពូជ................០៤

២. បច្ចេកទេសរៀបចំពូជ.....................០៥

៣. បច្ចេកទេសដាំដុះ...........................១៤

៤.បច្ចេកទេសថែទាំ............................១៦

V. បច្ចេកទេសប្រមូលផល...............................១៩



# ដំណាំក្រូចពោធិសាត់

## I- សារៈប្រយោជន៍

ក្រូចជាឈើហូបផ្លែមួយប្រភេទ ដែលប្រជាជនកម្ពុជា ក៏ដូចជាប្រជាជន នៅទូទាំងពិភពលោកនិយមបរិភោគ ។ ជាទូទៅគេច្រើនបរិភោគផ្លែស្រស់ ដូចជាក្រូចពោធិសាត់ ក្រូចថ្លុង និងក្រូចឃ្វិច ជាដើម ជួនកាលគេអាចផ្សំជាមួយគ្រឿងម្ហូប ដូចជាក្រូចឆ្មារ ឬ ក្រូចពោធិសាត់ ដោយសាររសជាតិជូររបស់វា។

ក្រូចពោធិសាត់ សាច់របស់វាសម្បូរ ទៅដោយជាតិវីតាមីនសេ ច្រើនជាងគេ គឺដល់ទៅ ៦០មីលីក្រាម ក្នុងទឹកក្រូច ១០០ក្រាម ។ ប៉ុន្តែផ្លែឈើនេះមានជាតិប្រូតេអ៊ីនតិច។ ក្នុងទឹកក្រូចពោធិសាត់១០០ក្រាម អាចផ្តល់ថាមពលប្រមាណជា ៣៥កាឡូរី និងក្លុយស៊ីតពី ៧ ទៅ ៨ ភាគរយ។







ក្រូចឃ្វិចគឺជាផ្លែឈើ ដែលគេនិយម បរិភោគផ្លែស្រស់តែម្តង។ ផ្លែក្រូចប្រភេទនេះ មានជាតិវីតាមីនសេតែ ១ភាគ ៣ នៃក្រូចពោធិសាត់ ម៉្យាងវិញទៀតក្រូចនេះគេអាចកែច្នៃធ្វើជាដំណាប់ដែលអាចទុកបានយូរ ។

ចំពោះក្រូចឆ្មារវិញ អាចចាត់ទុកជាគ្រឿងផ្សំមួយប្រភេទ ដែលមិនអាចខ្វះបាន ក្នុងការធ្វើម្ហូបអាហារ ព្រោះទឹកក្រូចឆ្មារ មានជាតិជូរម៉្យាងដែលធ្វើឱ្យយើងចង់បរិភោគ ។

ក្រូចឆ្មារ ក៏មានជាតិវីតាមីនសេ ច្រើនដូចក្រូចពោធិសាត់ដែរ គឺក្នុងទឹកក្រូចឆ្មារ ១០០ក្រាម អាចផ្តល់វីតាមីន ៦០ ម.ក្រ ។ ក្រៅពីការកែច្នៃជាម្ហូបអាហារ ក្រូចឆ្មារ គេអាចប្រើប្រាស់ជាឱសថសម្រាប់ ព្យាបាលជំងឺឈាមជើងធ្មេញ និង អាចយកមកធ្វើជាដំណាប់បានដែរ ។

Citrus aurantifolia



ក្រៅពីបំរើសេចក្ដីត្រូវការ ជាចំណីអាហារ ដំណាំក្រូចអាចកែច្នៃដោយយកស្លឹក និងសំបក ដើមធ្វើជាវត្ថុធាតុដើម សម្រាប់ឧស្សាហកម្ម ធ្វើទឹកអប់ សាប៊ូ និងស្រា ។ ផលប្រយោជន៍សំខាន់មួយទៀត គឺជាវត្ថុធាតុដើមសម្រាប់ឱសថមួយចំនួន ដែលគេទាញយកនូវជាតិវីតាមីនសេ និងជាតិប្រេងក្នុងស្លឹក។

## II- តំបន់ដាំដុះ:

ក្រូចជាប្រភេទរុក្ខជាតិម៉្យាង ដែលទាមទារអាកាសធាតុ ទឹក ដី ដែលសមស្រប ដូចជាដីស្រទាប់ទីមួយ ធូរ ជ្រៅ ស្រោះទឹកល្អ មានជីជាតិគ្រប់គ្រាន់ និងតំបន់ដែលមានភ្លៀងធ្លាក់ច្រើន។

នៅប្រទេសកម្ពុជាយើង ដំណាំនេះច្រើនដាំដុះនៅតាមតំបន់ដីទួលតាមដងទន្លេនិងតំបន់ខ្ពស់រាបដូចខេត្តបាត់ដំបង កំពង់ចាម ក្រចេះ កណ្ដាល និងព្រៃវែង ។



ការដាំដុះដំណាំនេះជាទ្រង់ទ្រាយធំ គឺគេសង្កេតឃើញមាននៅខេត្តបាត់ដំបងប៉ុណ្ណោះ ។ ចំពោះតំបន់ផ្សេងទៀត ច្រើនតែជាចម្ការតូច ។ ឬជាលក្ខណៈគ្រួសារប៉ុណ្ណោះ ។

## III- បច្ចេកទេសដាំដុះ និងថែទាំ:

ដំណាំក្រូចជាដើមឈើហូបផ្លែម្យ៉ាង ដែលមានអាយុវែង ដូច្នេះបច្ចេកទេសដាំដុះនិងថែទាំ គឺទាមទារនូវ លក្ខណៈពិសេសមួយចំនួនខុសពីដំណាំចម្ការធម្មតា។ ការរៀបចំដីចម្ការ និងការជ្រើសរើសពូជ ជាការងារមួយចាំបាច់បំផុតដែលត្រូវអនុវត្តឱ្យបានល្អសម្រាប់ដំណាំនេះ ។

### ១- ការជ្រើសរើសដី :

ដីដែលសមស្របល្អ សម្រាប់ដំណាំនេះ គឺដីដែលមានជីជាតិច្រើន ស្រទាប់ទី១ជ្រៅ ដីមិនដក់ទឹក ឬជាំទឹក គឺដីទួល ឬ ដីដែលស្ថិតនៅតាមតំបន់ខ្ពស់រាប និងដីដែលមាន PH ប្រហែល ៦,៥ ។



## ២- បច្ចេកទេសរៀបចំពូជ៖

ជាទូទៅគេអាចដាំក្រូចតាមវិធី ៣យ៉ាង:

២.១ ការបណ្តុះដោយគ្រាប់ ( Seed Progation )

២.២ ការបំបៅមែក ( Microstting )

២.៣ ការផ្សាំត្នួលមែកនៃដើមមួយ និងបណ្តុះដើមមួយទៀត ( Grafting ) ។

ក្នុងចំណោមវិធីទាំង ៣ យ៉ាងនេះ គឺមានវិធីសាស្ត្រមួយដែលល្អនឹងផ្តល់ផលខ្ពស់ជាងគេ គឺការដាំ ដោយមែកផ្សាំ ។ ចំពោះប្រទេសកម្ពុជាប្រជាកសិករយើងនិយមដាំដោយមែកបំបៅ ។

២.១ បច្ចេកទេសដាំដោយបណ្តុះគ្រាប់: វិធីនេះជាវិធីងាយស្រួលបំផុតដោយរៀបចំកន្លោង ដែលមានដីធម្មជាតិ ហើយដាក់គ្រាប់បណ្តុះតែម្តង ។ ជាទូទៅ មិនសូវអនុវត្ត តាមវិធីនេះទេ ព្រោះវាមិនងាយឱ្យផលយ៉ាងហោចណាស់ពី ៤ ទៅ ៥ ឬ ៦ ឆ្នាំទើបចាប់ផ្តើមឱ្យផល ។




២.២ វិធីសាស្ត្របំបៅមែក:

វិធីនេះជាវិធីមួយ ដែលប្រជាកសិករយើង និយមអនុវត្តរហូតដល់សព្វថ្ងៃនេះ ក្នុងការដាំដុះជាលក្ខណៈគ្រួសារ ឬចម្ការតូចៗ ។ បច្ចេកទេសនៃការរៀបចំពូជនេះងាយស្រួលក្នុងការអនុវត្តន៍ និងចំណាយទុនតិច ។ ប៉ុន្តែវិធីនេះ

ត្រូវចំណាយពេលវេលាច្រើន ហើយបរិមាណដើម ដែលអាចទទួលបានតិច ។ ការដាំដោយកូនបំបៅ ក្នុងរយៈពេលពី ២ ទៅ ៣ ឆ្នាំប៉ុណ្ណោះ ដើមក្រូចចាប់ផ្តើម ផ្តល់ផ្លែផ្កា ។ ប៉ុន្តែជាទូទៅ ដើមមានអាយុខ្លីឆាប់ងាប់ ។



*វិធីរុំបំបៅមែក*

## វិធីសាស្ត្រក្នុងការអនុវត្តន៍

- ត្រូវជ្រើសរើសយកមែកណាដែលមានអាយុចំណាស់ល្មម មានទំហំប្រមាណប៉ុនមេដៃ និងជាមែកដែលផ្តល់ផ្លែច្រើន និង គ្មានជំងឺបំផ្លាញ ។
- នៅលើមែកដែលត្រូវបំបៅប្រវែងប្រមាណ ១ម៉ែត្រពីចុងមែកត្រូវកាត់ជៀរសំបកមែកចោល ដែលមានទំហំប្រមាណ១.៥ស.ម ។
- ត្រូវយកដីលាយនិងជីធម្មជាតិស្ងួតបន្តិចមកបិទជុំវិញកន្លែងដែលបានចៀរសំបកចេញ បន្ទាប់មកយកស្រកីដូង ឬ ក្រណាត់មករុំព័ទ្ធជុំវិញពីក្រៅឱ្យបានជិតល្អ ។
- ជាការប្រសើរ ត្រូវអនុវត្តភ្លាមនៅរដូវភ្លៀង ទើបអាចឱ្យដីបិទជុំវិញមែកនោះ នៅសើមជាប់ជានិច្ច ។ ក្នុងករណីដែលពុំសូវមានភ្លៀងគ្រប់គ្រាន់ ត្រូវសម្រកទឹកលើស្រកីដូងនោះ ដើម្បីឱ្យវានៅសើម ។
- ប្រមាណពី ២ ទៅ ៣ខែ កន្លែងដែលគេបានបិទដីនេះ មានឫសដុះចាក់ចេញមក ។ ពេលដែលយើងឃើញមានឫស ដុះចាក់ច្រើន

ល្មមហើយ យើងអាចកាត់យកមកផ្សាំក្នុងកន្ទោងសិន មុនពេលយកទៅដាំផ្ទាល់នៅក្នុងចម្ការ ។



## ២.៣ វិធីផ្សាំដោយការបិទពន្លក និងការផ្សាំមែកៈ

ក្នុងការផ្សាំនេះ គឺយើងជ្រើសរើសរកពូជណា ដែលមានប្រព័ន្ធឫស រឹងមាំល្អ សមស្របនឹងលក្ខណៈរបស់ដីចម្ការ និងពូជ ដែលមានលក្ខណៈសម្បត្តិដើមដងល្អ ទិន្នផលខ្ពស់មកផ្សាំចូលគ្នា ។

វិធីនេះ គេនិយមអនុវត្តពេល



ដែលគេត្រូវការកូនច្រើនសម្រាប់ដាំចម្ការធំ ។ បច្ចេកទេសនេះ ទាមទារនូវថវិកាច្រើនសម្រាប់អនុវត្ត ប៉ុន្តែយើងអាចបណ្តុះកូនក្រូចបានច្រើនហើយប្រកបដោយគុណភាពល្អ ព្រមទាំងចំណាយពេលខ្លី ។ ដើមក្រូចដែលដាំតាមវិធីនេះ គឺអាចមានអាយុ រហូតដល់ ១៥ ទៅ ២០ឆ្នាំ ទើបងាប់ដើម ។ ម្យ៉ាងវិញទៀតអាយុដែលអាចបេះផ្លែបាន ក៏ខ្លីដែរ គឺប្រមាណពី ៣ ទៅ ៤ឆ្នាំ ប៉ុណ្ណោះ ។

### ក- បច្ចេកទេសផ្សាំដោយបិទពន្លក:

#### វិធីសាស្ត្រក្នុងការអនុវត្តន៍

- ត្រូវជ្រើសរើសរកប្រភេទពូជក្រូចណាដែលមានប្រព័ន្ធឫសរឹងមាំ ធន់ទ្រាំនឹងជំងឺ និងសត្វល្អិតក្នុងដី ហើយជាប្រភេទក្រូចដែលមានដើមធំ។ ត្រូវយកគ្រាប់ពូជក្រូចនេះទៅបណ្តុះនៅក្នុងថង់ប្លាស្ទីក ដែល មានដាក់ដីលាយជាមួយជីធម្មជាតិ ដើម្បីទុកធ្វើជាផ្នែកផ្សាំខាងក្រោម ( Root Stock )
- ត្រូវជ្រើសរើសរកប្រភេទពូជ ឬ ដើមក្រូចណាដែលមានដើមដងល្អ ផ្តល់ទិន្នផលខ្ពស់ ហើយធន់នឹង ជំងឺផ្សេង ។ បន្ទាប់មកត្រូវជ្រើសរើសយកមែក ដែលនៅខ្ចីល្មម មានពន្លកល្អៗសម្រាប់យកពន្លក មកបិទផ្សាំ ។
- កូនក្រូចដែលបណ្តុះសម្រាប់ធ្វើជាទម្រផ្នែកគល់ ( Root Stock ) ពេលវាដុះបានកម្ពស់ប្រមាណ១ម៉ែត្រ ទំហំប្រមាណប៉ុនម្រាមដៃ អាចចាប់ផ្តើមធ្វើការបន្សាំបាន ។
- ត្រូវចៀរកូនក្រូចដែលបានបណ្តុះកម្ពស់ប្រមាណ ០,៤០ ម៉ែត្រពីគល់ ជារាងអក្សរតេ ( T ) ឬតេផ្កាប់ វិធីម្យ៉ាងទៀតនោះគឺយើងចៀរដល់សាច់ក្នុងនូវទំហំល្មមប៉ុនពន្លកដែលត្រូវដាក់បន្សាំ។

# បច្ចេកទេសផ្សាំបិទពន្លកជាអក្សរ T



# បច្ចេកទេសផ្សាំដោយសំបកមានពន្លកបិទ



- កាត់យកពន្លកពីមែក កុំឱ្យបាក់ ឬ ចៀរជិតពន្លកពេក ។
- ដាក់ពន្លកដែលត្រូវផ្សាំ ចូលទៅកន្លែងដែលបានកាត់ នៃកូនដើមបណ្តុះ ។ បន្ទាប់មក ត្រូវរុំដោយស្បោងប្លាស្ទិក ដើម្បីឱ្យពន្លក និងដើមស៊ីសាច់គ្នាល្អ ។ មិនត្រូវរុំស្បោងផ្លាស្ទិក ឱ្យជិតទាំងអស់ទេ គឺយើងត្រូវទុកចន្លោះសម្រាប់ពន្លកដុះចេញមកក្រៅ ។
- បន្ទាប់ពីពន្លកផ្សាំដុះ ត្រូវកាត់ដើមផ្នែកខាងចុងនៃដើមផ្នែកគល់ចោល ( Root Stock ) ។

* រយៈពេលប្រមាណជាង១៤ថ្ងៃបន្ទាប់មកយើងអាចពិនិត្យមើលពន្លកបើពន្លកនៅស្រស់ធម្មតាទេ " នៅរស់ " យើងអាចស្រាយស្បោងប្លាស្ទិកចេញបាន ។ បន្ទាប់ពីពន្លកនេះដុះលូតលាស់បានល្អហើយ យើងត្រូវកាត់ចុងនៃកូនដើមបណ្តុះចោល ដើម្បីទុកឱ្យដើម ដែលដុះចេញពីពន្លកផ្សាំនោះលូតលាស់ជាធម្មតា ។

- បន្ទាប់ពីដើមថ្មី ដែលដុះចេញមកនោះ មានកម្ពស់ប្រមាណជា១ម៉ែត្រ ត្រូវកាត់ចុងដើមដុះចេញ ពីកន្លកម្តង ដោយទុកកម្ពស់ប្រមាណពី ៦០ ទៅ ៧០ស.ម ពីដី ។ ការអនុវត្តបែបនេះ គឺដើម្បីឱ្យកូនក្រូចនោះចាប់ផ្តើមបែកមែកច្រើន ។

## ខ- ការផ្សាំដោយត្នូលមែក:

- ដូចគ្នានឹងការផ្សាំដោយពន្លកដែរ គេអាចផ្សាំមែកដែលចេញពីពូជមានទិន្នផលខ្ពស់ មកផ្សាំជាមួយគល់នៃដើមពូជផ្សេងទៀត ( សូមមើលរូប ) ។

# បច្ចេកទេសផ្សាំដោយត្បុលមែក


















# របៀបផ្សាំត្នុលម៉្យាងទៀត




## គ- ការផ្សាំដោយចងមែកផ្អោប:





ចង់ផ្គោបមែកនឹងគល់



រយៈពេល ១-៣ ខែ ឬក្រោយពេលដុះស៊ីគ្នារួច ត្រូវកាត់មែករបស់គល់ផ្សាំ និងគល់មែកផ្សាំចោល។

## ៣ - បច្ចេកទេសដាំដុះ

- មុននឹងអនុវត្តការកាប់រណ្តៅ ត្រូវភ្ជួររាស់ដីចម្ការឱ្យបានស្អាតកុំឱ្យមានស្មៅ ហើយត្រូវបំផុសដី ។
- ត្រូវបោះបង្គោលតូចៗ សម្រាប់សម្គាល់កន្លែង ដែលត្រូវកាប់រណ្តៅ ។ វិធីនេះយើងអាច តម្រង់រណ្តៅដែលត្រូវកាប់បានត្រង់ល្អ ។
- ជាការល្អប្រសើរ រណ្តៅត្រូវកាប់រាងមូល ដែលមានទំហំពី ៦០ ទៅ៨០ ស.ម និងជម្រៅពី ៥០ ទៅ ៦០ស.ម ។
- ចន្លោះពីរណ្តៅមួយ ទៅរណ្តៅមួយ អាចប្រែប្រួលដោយទៅតាមប្រភេទពូជ បច្ចេកទេសថែទាំដំណាំក្រូច និងប្រភេទដី ។ ល ។

ជាទូទៅចន្លោះឃ្លាតពីរណ្តៅមួយទៅរណ្តៅមួយ គឺ ៤ម៉ែត្រ ប៉ុន្តែបើការប្រមូលផលត្រូវធ្វើឡើងដោយប្រើត្រាក់ទ័រ ចន្លោះរណ្តៅចម្ងាយពី ៨ ទៅ ១០ ម៉ែត្រ ។



- មុនពេលដាំត្រូវដាក់ជីទ្រាប់បាត ដោយប្រើជីធម្មជាតិ ស្ងួត លាយនឹងជីគីមីនូវបរិមាណ មួយសមស្រប (សូមមើល ក្នុងចំណុច ៤.១ ស្តីពីការដាក់ជី)។
- ពេលដាក់ដាំ ត្រូវមានការប្រុងប្រយ័ត្ន ។ ត្រូវលើកទ្រថង់ឬ កន្ទោងកូនក្រូចឱ្យបានត្រឹមត្រូវ ជៀសវាងការបោះបោក ឬ លើកដើមយូរ ។ មុននឹងដាំត្រូវកាត់ ឬ បកថង់ចេញ។ ក្នុងការកាត់ថងចេញត្រូវប្រុងប្រយ័ត្នកុំឱ្យបែកខ្វាយដី ដែលអាចបណ្តាលឱ្យប៉ះពាល់ដល់ប្រព័ន្ធឫស ។
- ពេលដាក់ដាំត្រូវលប់ដី ដោយទុកជម្រៅពីមាត់រណ្តៅខាងលើ ប្រមាណពី ១០ ទៅ ១៥ស.ម ដើម្បីងាយស្រួលក្នុងការបញ្ចូលទឹក និងដាក់ជីបំប៉ន។ ប៉ុន្តែបើការដាំដុះចំពេលភ្លៀងច្រើនយើងត្រូវលប់ដីស្មើមាត់រណ្តៅ ឬ លើមាត់រណ្តៅបន្តិច ជៀសវាងកុំឱ្យទឹកដក់ខ្លាំងពេក ។





## ៤- បច្ចេកទេសថែទាំ:

៤-១ ការដាក់ជី: ដំណាំក្រូចក៏ដូចជាដំណាំផ្សេងទៀតដែរ គឺទាមទារការដាក់ជីជារៀងរាល់ឆ្នាំ ដើម្បីឱ្យដំណាំលូតលាស់ល្អ និងផ្តល់ទិន្នផលខ្ពស់ ។ ចំពោះដំណាំក្រូច បរិមាណនៃការដាក់ជីគឺអាចប្រែប្រួលតាមកត្តាជាច្រើន ដូចជាដី អាកាសធាតុ អាយុកាល នៃការលូតលាស់ទំហំដើម និងពូជក្រូចដែលបានដាំ ។ បរិមាណជីគីមី ដែលត្រូវដាក់ នៅពេលដាំ (ជីទ្រាប់បាត) ជាមធ្យមគឺជី ១៥-១៥-១៥ ពី ៤០០ ទៅ ៦០០ គ.ក្រ ក្នុងមួយហិកតា ។ បន្ទាប់ពី ដំណាំលូតលាស់បានធំហើយ យើងត្រូវដាក់ជីបំប៉នដែលមានជាតិអាហ្សូត " អ៊ុយរ៉េ " ជារៀង រាល់ឆ្នាំក្នុងបរិមាណជាមធ្យមអាហ្សូត ៦០០ ក្រាម (អ៊ុយរ៉េ= ១.៣ គ.ក្រ) ក្នុងមួយដើម ដើម្បីជួយដល់ការលូតលាស់ និង ចេញផ្កាផ្លែ ។





### ៤.២ បច្ចេកទេសកាត់មែកមិនល្អចោលដើម្បីលំអទ្រង់ទ្រាយដើម៖

ការងារនេះមានសារៈសំខាន់ណាស់ សម្រាប់ដំណាំក្រូច។ តាមរយៈការអនុវត្តកន្លងមកយើងអាចទទួលបរិមាណផលកើនឡើងច្រើនបើប្រៀបធៀបទៅនឹងចម្ការ ឬដើមណាដែលពុំបានអនុវត្តការងាររបៀបនេះ។យើងអាចទទួលបាន នូវដើមក្រូចដែលបែកមែកសាខាល្អ ហើយដើមទាំងមូលមានរាងល្អ ។ ការងារនេះ យើងចាប់ផ្តើមអនុវត្តចាប់តាំងពីដើមនៅតូចក្នុងថ្នាលបណ្តុះ ។

- បន្ទាប់ពីផ្សាំកូន កម្ពស់ប្រមាណជា ១ ម៉ែត្រ គឺយើងត្រូវកាត់ចុង ចោលទុកត្រឹមកម្ពស់ប្រហែល ពី ៦០ ទៅ ៨០ ស.ម ពីដី ។ យើងធ្វើដូច្នេះគឺដើម្បីឱ្យដើម ចាប់ផ្តើមបែកមែកថ្មី ពី ៣ទៅ ៥ ថៃមទៀត ។
- ចំពោះដើមធំយើងអាចកាត់ចុងមែកចោល ពី ២ ទៅ ៣ ឆ្នាំម្តង ។ យើងអនុវត្តបែបនេះ គឺដើម្បីឱ្យដើម បន្តបែកមែកទៀត ។



- យើងត្រូវការកាត់មែកបំពង់ ដែលលាស់ខ្ចី នៅផ្នែកខាងក្នុង នៃដើមចោល។ ព្រោះស្លឹក និងមែកទាំងនោះ មិនទទួលពន្លឺបានគ្រប់គ្រាន់ ហើយវាក៏មិនអាចបង្កើតជាផ្កាផ្លែបានដែរ។
- ការងារមួយទៀត គឺយើងត្រូវកាត់មែក ដែលងាប់ៗចោល ព្រោះមែកទាំងនោះ អាចបណ្តាលឱ្យឆ្លងជំងឺផ្សេងៗ ឬ ជាជម្រករបស់សត្វល្អិតចង្រៃមួយចំនួន ។



៨.៣ ការសម្អាតស្មៅ: ការងារនេះ យើងត្រូវអនុវត្តចាប់តាំង ពីពេលដើមក្រូចនៅតូចៗ រហូតដល់ដើមធំ ។ ពេលដើមនៅតូច យើងត្រូវជម្រះស្មៅប្រហែលជា ១ម៉ែត្រជុំវិញគល់ និងដីដែលនៅចន្លោះជួរ។ យើងអាចភ្ជួរលប់ដោយនង្គ័លគោ ឬ ដោយត្រាក់ទ័រ ។ វិធីម៉្យាងទៀត នៅពេលដើមធំល្មម (អាយុ៥ឆ្នាំឡើងទៅ) គឺគេអាចចិញ្ចឹមសត្វពពែ ឬ ចៀមក្នុងចម្ការដើម្បីឱ្យសត្វទាំងនោះដើរស៊ីស្មៅក្នុងចម្ការ ។



## IV- **បច្ចេកទេសប្រមូលផល:**

ចំពោះចម្ការក្រូចដែលដាំដោយកូនផ្សាំ យើងអាចចាប់ផ្ដើមប្រមូលផលនៅពេលដែលដើម អាយុបានប្រមាណពី ៣ ទៅ ៤ ឆ្នាំបន្ទាប់ពីពេលដាំ ។ គេអាចកត់សម្គាល់ផ្លែក្រូចទុំ នៅពេលសំបកផ្លែប្រែពណ៌ពីបៃតងមកភ្លឺរលោង ឬ លឿងទុំ ឬ លឿង និងការកើនឡើងនូវជាតិផ្អែម តែផ្ទុយទៅវិញ ជាតិជូរមានការថយចុះ ។ក្នុងករណីយើងចង់រក្សាទុកផ្លែក្រូចឱ្យបានយូរថ្ងៃ យើងត្រូវប្រមូលផលផ្លែក្រូច យ៉ាងណាជៀសវាងការបេះទម្លាក់ ព្រោះអាចបណ្ដាលឱ្យផ្លែឆាប់ជាំ និងរលួយ ។ ទិន្នផលផ្លែក្រូចជាមធ្យម គឺប្រហែលពី ២០ ទៅ ៣០ តោនក្នុងមួយហិកតា ៕





## ឯកសារយោង:

១. ដំណាំក្រូច និងពូជក្រូច មន្ទីរកសិកម្មខេត្តបាត់ដំបង ១៩៩៧
២. ដំណាំក្រូចពោធិសាត៏ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ២០០៣
៣. ម៉ូឌុលបណ្ដុះបណ្ដាលស្ដីពីដំណាំឈើហូបផ្លែ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ២០១៣ ៕